ខ្មែរប៉ុស្តិ៍ ស.រ.អា
KhmerPost USA
Printing The Cambodian World News
VOL. 06 ISSUE 89 Aug 30th - Sept 9th, 2011
សុបិន : (267) 253-3947, សែម : (781) 244-0522
MASSACHUSETTS
217 APPLETON ST.
LOWELL, MA 01852
PENNSYLVANIA
438 LINDLEY AVE.
PHILADELPHIA, PA 19120
RHODE ISLAND
NEW JERSEY

មាតិការឿង ទំព័រ

១- ប្រទេសលីប៊ី កាដាហ្វី និងប្រទេសស៊ីរីក៏នៅ........០៣
២- គឹម សុខា : ហ្វីឡាដែលហ្វៀ , អង់ទ្រី ភ្លក់ម្ហូប........០៤
៣- រញ្ជួយដីនៅជ្រោយខាងកើត ០៧
៤- បុណ្យពុទ្ធាភិសេកនៅវត្តព្រះពុទ្ធរង្សី........០៧
៥- ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ........១០
៦- ប្រវត្តិសាស្ត្រកម្ពុជា........១៨
៧- The Cambodia Daily........០៨ & ១៥

បុណ្យអុំទូកនៅ ហ្វីឡាដែលហ្វៀបន្ត

●●● ប្រធានគណកម្មការបុណ្យអុំទូកហ្វីឡាដែលហ្វៀ រៀបចំឡើងដោយវត្តព្រះពុទ្ធរង្សីតំណាងដោយលោក សុង ភូ បានឱ្យដឹងថា : កម្មវិធីអុំទូកខ្មែរសម្រាប់ថ្ងៃទី១០កញ្ញាកំពុងមានដំណើរការល្អ ដោយមកទល់ពេលនេះមានក្រុមអុំទូកចូលប្រកួតចំនួន១២ក្រុមបានចុះឈ្មោះ ដោយក្នុងនោះមាន

តទៅទំព័រទី ០៧

ខ្យល់ព្យុះ អាយរីន បោកបក់ ឆ្នេរខាងកើត ស.រ.អា

ខ្មែរប៉ុស្តិ៍ ហ្វីឡាដែលហ្វៀ



ចុងសប្តាហ៍ថ្ងៃទី ២៦ ខែ សីហា នេះ ខ្យល់ព្យុះបានបោកបក់ក្នុងកំរិត៣ "លើឆករដ្ឋហ្វ្លរីដា" យ៉ាងខ្លាំងក្លា ហើយបន្តដំណើរតាមឆ្នេររដ្ឋ "ណតការ៉ូឡាយណា" "រដ្ឋវៀរជីនីញ៉ា" (ឆ្នេរមុទ្រ) បង្កើត

តទៅទំព័រទី ៦

GRAND OPENING!
Kavei
ម្ហូបខ្មែរទាន់ចិត្ត
OPENING AUGUST 20, 2011
10am-7pm
2223-25 S. 7th STREET, PHILADELPHIA PA 19148
215.463.1950
KAVEI Xpress CAMBODIAN RESTAURANT
Authentic Khmer Cuisine • Eat In • Take Out

BUY RITE 267-297-5879
ឱសថស្ថានខ្មែរ
BUY RITE 267-297-5879
ឱសថការីខ្មែរ ជែន ចាច់ នៅ Old York Rd និង Rockland St
- ផ្ញើថ្នាំជូនដល់ផ្ទះដោយឥតគិតថ្លៃ
- ទទួលអ៊ិនស្ហូរិនស្ទើរគ្រប់មុខ
- ទទួលបន្តផ្តល់ថ្នាំដែលលោកអ្នកកំពុងប្រើទិញមកពីឱសថស្ថានផ្សេងៗ
- តម្លៃថោកៗបំផុត និងមានស្តុកឱសថគ្រប់មុខប្រភេទ
- ផ្តល់សេវាដោយរហ័សទាន់ចិត្ត
- មានឱសថវីតាមីន-ឱសថចិនសែ និងឧបករណ៍ព្យាបាលមុខជំងឺ

បណ្ណរង្វាន់ $30
សំរាប់ភ្ញៀវដែលមានអាយុពី៦៥ឡើងទៅបើផ្ទេរបញ្ជាទិញថ្នាំពីរ ឬលើស យើងនឹងជូនបណ្ណរង្វាន់៣០ដុល្លារ សំរាប់អ្នកមាន Insurance បណ្ណរង្វាន់មួយសំរាប់ភ្ញៀវ១នាក់ មិនអាចផ្ទេរឱ្យអ្នកដ៏ទៃ ផ្តល់រង្វាន់នេះ ក្នុងរយៈពេលខ្លី ហើយយើងខ្ញុំមានសិទ្ធិនឹងបញ្ឈប់ដោយមិនចាំបាច់ប្រាប់មុន

ម៉ោងធ្វើការ :
ច័ន្ទ-សុក្រ : 9am-7pm
សៅរ៍ : 9am-5pm
អាទិត្យ : បិទទ្វារ

1337 W. Rockland St.
Philadelphia, PA 19141
Tel: 267-297-5879
Fax: 267-297-5880

Free $30 Gift Card
with two or more new or transferred prescriptions.
Limit one per customer. non-transferable, for Limited time only. Buy Rite has the right to cancel the promotion at any time without notice. Disclaimer: This discount is not insurance. Offer not valid with prescriptions covered by medicaid, Medicare, or any other governmental pay programs or where prohibited by law.



របួសដោយគ្រោះថ្នាក់រថយន្ត និងគ្រោះថ្នាក់ក្នុងការងារ

AUTOMOBILE INJURY
WORK INJURY

YOU MAY HAVE THE RIGHT FOR A COMPLETE TREATMENT WITHOUT ANY COST

លោកអ្នកអាចនឹងមានសិទ្ធ ដើម្បីទទួលការព្យាបាល
ឱ្យបានគ្រប់គ្រាន់ដោយមិនចាំបាច់បង់ថ្លៃ

NECK & BACK PAIN
SPORTS INJURY
CHRONIC/ARTHRITIC PAIN
PREGNANT PATIENTS OK

ឈឺកញ្ចឹងក ឬឈឺឆ្អឹងខ្នង
របួសដោយកីឡា
ឈឺជាប្រចាំ ឬឈឺសន្លាក់ដៃជើង
អាចទទួលអ្នកជំងឺមានផ្ទៃពោះ

CALL NOW
WE SPEAK CAMBODIAN
617-202-9225
FIRST CONSULTATION FREE

សូមទូរស័ព្ទមករកយើងខ្ញុំ
យើងនិយាយភាសាខ្មែរ
617-202-9225
ថ្ងៃពិគ្រោះទី១ មិនយកថ្លៃ

REVERE REHABILITATION CENTER REVERE -JAMAICA PLAIN

Mandarin Buffet
Parkway Plaza
1100 Revere Beach Parkway
Chelsea, MA 02150
617-889-0056
WWW.mandarinbuffetma.com
We have a full liquor license

China Buffet
Next to Target
203 Plain St.
Lowell, MA 01852
978-937-8868
WWW.chinabuffetma.com
Beer and Wine only

China Buffet
K-Mart Plaza180 Main
St.Saugus, MA 01906781-231-1588
Beer and Wine only

Buffet includes American & Chinese food bar, Japanese sushi bar, BBQ & grill, fruits,salad bar, ice cream, dessert cakes and much much more!

ALL YOU CAN EAT BUFFET... !!!

ប្រទេសលីប៊ី កាដាហ្វី លែងធ្វើឱ្យគេខ្លាចទៀតហើយ

●●●កូឡូណែល កាដាហ្វី ឡើងកាន់អំណាចលើប្រទេសលីប៊ី៤២ឆ្នាំហើយដោយរដ្ឋប្រហារប្រជាពលរដ្ឋប្រទេសលីប៊ីមានការធុញថប់ និងអំណាចផ្តាច់ការរបស់ជនជាប្រមុខនោះ ក៏នាំគ្នាកាន់អាវុធប្រមូលគ្នាបណ្តេញប្រមុខនៃប្រទេសខ្លួន ដែលកាន់ចង្កូតប្រទេសមិនព្រមលែង ។ កម្លាំងប្រដាប់អាវុធដែលផ្តើមពី៦ខែមុន ឥឡូវកម្លាំងរហូតដល់វាយយករដ្ឋធានីនយោបាយទ្រីប៉ូលី បានកាលពីចុងសប្តាហ៍ទី២០ខែសីហាមុននេះ ។

ក្រុមប្រជាពលរដ្ឋដែលដឹកនាំដោយក្រុមប្រឹក្សាជាតិ បានរុញច្រានកងកម្លាំងពិសេសរបស់ កាដាហ្វី ដែលប្រើទ័ពស៊ីឈ្នួលមកពីបរទេស ដោយមានការទទួលស្គាល់ពីសហគមន៍អឺរ៉ុប ពីអាមេរិក ហើយការពារពីលើអាកាសដោយទ័ពអូតង់ ។ ដំណាក់ការណ៍ចុងក្រោយបានចូលមកដល់ទ័ពប្រជាពលរដ្ឋបានចូលកាន់កាប់ក្រុមទ្រីប៉ូលីមួយសប្តាហ៍ហើយចាប់បានកូនប្រុស កាដាហ្វីម្នាក់ កូឡូណែល កាដាហ្វី ទំនងជានៅលាក់ខ្លួននៅទីណាមួយនៃក្រុងទ្រីប៉ូលីនៅឡើយ ។

កាដាហ្វី មានឈ្មោះជាជនឧក្រិដ្ឋត្រូវក្រុមប្រឹក្សាជាតិរកចាប់ខ្លួនដោយអំពើសម្លាប់មនុស្ស អំពើរំលោភបំពានសិទ្ធិមនុស្ស ។ អំណាច កាដាហ្វី នៅរួញមកត្រឹមការពារខ្លួនឯងមិនបាន មិនអាចធ្វើឱ្យនរណាខ្លាចទៀតទេ ។

ដោយ : ខ្មែរប៉ុស្តិ៍

ប្រទេសស៊ីរីក៏នៅក្បែរជ្រោះ

●●●ការបះបោរនៅពិភពអារ៉ាប់បានប៉ះពាល់យ៉ាងដំណំទៅលើការគ្រប់គ្រងនៃប្រទេសស៊ីរី ថ្ងៃ១៥មិនាឆ្នាំ២០១១ប្រជាពលរដ្ឋស៊ីរីបានផ្តើមប្រឆាំងនឹងអំណាចផ្តាច់ការនឹងគ្រួសារនិយមរបស់ បាចា អែល អាសាដ ដែលបានកាន់អំណាចបន្តពីឪពុកដោយសារការធ្វើប្រជាមតិនៅឆ្នាំ២០០០ រីឯឪពុកឈ្មោះ ហាហ្វែ អែលអាសាដ បានឡើងកាន់អំណាចកាលពីឆ្នាំ១៩៧០ដោយរដ្ឋប្រហារ បូករួមទាំងអស់មានការកាន់អំណាច៤១ឆ្នាំ ការរើបំរះលើគ្រប់កន្លែង កាលពីខែមីនាឆ្នាំ២០១១នេះ នៅស៊ីរីបានទទួលការបង្ក្រាបយ៉ាងចាស់ដៃបណ្តាលឱ្យអង្គភាពប្រជាជាតិបន្ទោសពីការបាត់បង់ជីវិតបាតុករប្រមាណ១៤០០នាក់ ទាហានខ្លះបាក់ទឹកចិត្ត ហើយទៅចុះចូលចលនាបះបោរថែមទៀត ។ ថ្វីត្បិតតែការបង្ក្រាបបានបង្កើនកម្លាំងតាំងពីខែមេសាមកភាពរំជើបរំជួលនៅតែមាន សភាពអឺរ៉ុប អាមេរិក នឹងអង្គការសហប្រជាជាតិ បានដាក់ដង្ហៀបលើប្រធានាធិបតី បាចា អែល អាសាដ ឱ្យប្រើលទ្ធិប្រជាធិបតេយ្យ នឹងគោរពសិទ្ធិពលរដ្ឋរបស់ខ្លួន ។

ដូចគ្នានឹងប្រទេសលីប៊ីប្រទេស ស៊ីរី នៅមាត់ជ្រោះដ៏ជ្រៅនៃការប្តូររបបនៅក្នុងប្រទេស នឹងនៅក្នុងតំបន់ ។ របបផ្តាច់ការដែលជនផ្តាច់ការជាច្រើនប្រើក្រោមឆ័ត្រនៃសាសនា នឹងក្រោមឆ័ត្រនៃសម្ព័ន្ធភាពជាមួយបរទេស ពុំបានលាក់ជិតនៅក្នុងសម័យព័តិមានសេរីបានត្រូវហូរហៀរតាមរយៈបច្ចេកវិជ្ជាទំនើបការកាត់ផ្តាច់ឫសនៃមេដឹកនាំដ៏កំសត់ទាំងនោះមិនឱ្យចាក់ឫសមាំទាំទៅបាន។

ដោយ : ខ្មែរប៉ុស្តិ៍

GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)

DR. SERENA B. CHUOP

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.



WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN
- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ើរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

www.gatewayfamilydental.com

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH FOR KIDS
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth for Kids
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

កឹម សុខា : ហ្វីឡាដែលហៀ នៅតែទីក្រុង ដ៏រឹងមាំសម្រាប់បក្សសិទ្ធិមនុស្ស

ដោយ : អ៊ុំ លឿម

ថ្លែងទៅកាន់សមាជិក សមាជិកា និងថ្នាក់ដឹកនាំសំខាន់ៗប្រមាណជា៣០នាក់ តាមប្រព័ន្ធទូរស័ព្ទកាលពីថ្ងៃអាទិត្យទី២១ សីហា កន្លងមកនេះ លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្សបានថ្លែងប្រាប់ដល់សកម្មជន និងអ្នកគាំទ្ររបស់ខ្លួនថា "បច្ចុប្បន្នគណបក្សសិទ្ធិមនុស្សកំពុងតែមានសន្ទុះទៅមុខយ៉ាងខ្លាំង និងមានអ្នកគាំទ្រកាន់តែច្រើនឡើងៗជាលំដាប់ ។ លោកបន្តថា : សព្វថ្ងៃរូបលោកផ្ទាល់ ក៏ដូចជាសកម្មជនថ្នាក់ដឹកនាំដទៃៗ ទៀត មានការធ្វើមារញ្ញឹកក្នុងការចុះតាមមូលដ្ឋានគ្រប់បណ្តាខេត្តក្រុងទាំងអស់ ពង្រឹងដល់សកម្មជនតាមភូមិ-ឃុំ ជាពិសេស គឺផ្តោតទៅលើក្រុមយុវជន ដែលពួកគេគឺជាកោសិកាសម្រាប់ប្រទេសជាតិ ។

លោក សុខា សំដែងដោយសុទិដ្ឋិនិយមថា "នៅឆ្នាំ២០១៣ខាងមុខ គណបក្សសិទ្ធិមនុស្សពិតជាយកជ័យជំនះលើគណបក្សប្រជាជនកម្ពុជា ដែលកំពុងងប់ងល់នឹងអំណាចពុំខាន បើសិនជាការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌មែននោះ" ប៉ុន្តែក្នុងគ្រាដំណាលគ្នានោះ លោក សុខា បានទទួលស្គាល់ថា បច្ចុប្បន្នរដ្ឋាភិបាលបានក្តោបក្តាប់ទៅលើប្រព័ន្ធឃោសនាទាំងស្រុងរួចទៅហើយដែលនេះជាហេតុនាំឱ្យមានការពិបាកក្នុងការផ្សព្វផ្សាយអំពីគោលការណ៍របស់បក្ស ដើម្បី

តទៅទំព័រទី០៧

អង់ទ្រូ ភ្លក់ម្ហូប "សាំភ្លីខ្មែរ"

ដោយ : ខ្មែរប៉ុស្តិ៍

បន្ទាប់ពីពិធីអុំទូកដ៏គគ្រឹកគគ្រេង នៅឡូវែលមក ស្រាប់តែមានអ្នកសារព័ត៌មានតាមទូរទស្សន៍ ដ៏ល្បីល្បាញម្នាក់ឈ្មោះ អង់ទ្រូ ជីមមើន ដោយសារការភ្លក់ម្ហូបអាហារនៃវប្បធម៌ផ្សេងៗ បានចូលមកភ្លក់ម្ហូបនៃស្នាដៃអាហារដ្ឋានខ្មែរឈ្មោះ "សាំភ្លីខ្មែរ" ដែលធ្វើឱ្យភាពគគ្រឹកគគ្រេងនៃការនិយាយពីម្ហូបខ្មែរនៅបន្តបានមួយរយៈទៀត ។

ក្រោមបការនៃអ្នកនិពន្ធ ម៉ូរ៉ន សរសេរឱ្យកាសែតឡូសាន់ ចេញផ្សាយនាថ្ងៃ២៥សីហានេះ អ្នកភ្លក់ម្ហូបចំឡែកៗពីគ្រប់ប្រទេសគ្រប់វប្បធម៌ ហើយបង្ហាញតាមទូរទស្សន៍ "ត្រាវែលឆាណែល" បានស្វែងរកវប្បធម៌ចម្លែកៗនៅតំបន់បូស្តុន ដើម្បីបង្ហាញដូចដែលធ្លាប់បង្ហាញពីមុនៗមក ពីរស់ជាតិនៃម្ហូបដូចជា ពស់, ចង្រិត ដែលវប្បធម៌ទូទៅពុំដែលហូប អង់ទ្រូ ជីមមើន បានរកឃើញអាហារដ្ឋានតូចច្រឡឹងមួយ នៅឡូវែល ដែលមានលក្ខណៈជាវប្បធម៌ខ្មែរ លក្ខណៈជាយុវជនជាអ្នកដឹកនាំសាំភ្លីខ្មែរ ហើយបានភ្លក់ "ស្លាបមាន់ហិរ" ដែលជាម្ហូបប្រចាំត្រកូល ហើយភ្លក់ភ្លាពោះគោទឹកប្រហុក ភ្លក់បបរសាមចូក ដែលពោះវៀនជ្រូក និងម្ហូបចម្លែកផ្សេងៗទៀត ដែលបការ ម៉ូរ៉ន នឹងរូបថត ដេវីដប្រូ បានណែនាំ

តទៅទំព័រទី ១១



East Coast Center
for Plastic & Laser Surgery
Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com



Skin Care Products
Tummy Tuck
Breast Lift
Beast Enlargement
Nose Surgery
Eyelid Surgery
Face Lift
Dermabrasion

ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន
អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ
កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។
និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត

381 West Broadway South Boston, MA 02127
(617) 464 - 0001

ក្រុមហ៊ុនធានារ៉ាប់រងដែលបាន
បំរើសង្គម២២ឆ្នាំហើយ
CONWAY INSURANCE

For over 22 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត
មុខរបរ និងសុខភាព
យើងនិយាយភាសាខ្មែរ

CONWAY
INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

www.ConwayInsurance.com
សូមសួររក Philip Muth, Philip@conway.com

ក្រុងខ្មែរ នៅឡុងប៊ិច និងឡូវែល

រូបថតភ្នំពេញប៉ុស្តិ៍ផ្សាយពីឡុងប៊ិច

ដោយ : ខ្មែរប៉ុស្តិ៍

ឡុងប៊ិច : ក្រុងខ្មែរ នៅឡុងប៊ិច ឆ្ពោះខាងលិចបានចាប់កំណើតតាមសេចក្តីសម្រេចរបស់ គណក្រុមប្រឹក្សាក្រុងឡុងប៊ិច នាថ្ងៃទី៣ កក្កដា ឆ្នាំ២០០៧ ដោយការបោះឆ្នោតសម្លេងយល់ព្រម ៨ទល់នឹង១ ។ ការចាប់កំណើតនេះជាមោទនភាពដ៏ថ្លៃថ្លារបស់ប្រជាជាតិមួយដែលធ្លាប់តែសកម្ម ធ្លាប់មានអត្តសញ្ញាណទាំងវប្បធមិនិងទាំងសង្គមយ៉ាងច្បាស់លាស់ ដែលបានមកតាំងទីចាក់ឬសគ្រួសារ តាំងតែពី ៣០ឆ្នាំមកហើយ ។

ទើបតែដើមខែកក្កដា ឆ្នាំនេះប៉ុណ្ណោះ គេមានការលើកផ្លាកកំណត់ព្រំដែន "ក្រុងខ្មែរ" លើផ្លូវអាណាហែម យ៉ាងសង្ហា មិនចាញ់ ឆាយណាថោន ឬប៊ីទីសាយគួន នោះឡើយ ។ អ្នកស្រីប្រធាន Cambodia Town Inc. បានឱ្យដឹងថា នៅមានផ្លាកសញ្ញាដូចគ្នានេះចំនួន១៤ទៀតនឹងត្រូវលើកឡើងមុនដំណាច់ឆ្នាំ ដើម្បីកំណត់ព្រំប្រទល់ភាគខាងជើង និងភាគខាងត្បូងឱ្យបានចប់ ។

កាសែតភ្នំពេញប៉ុស្តិ៍សរសេរផ្សាយជំរឿនប្រជាជននៅ ស.រ.អា ថាវត្តមានរបស់ជនជាតិដើមកំណើតខ្មែរមាន២៤១.០២៥នាក់ ហើយលោក ឆាង សុង អតីតរដ្ឋមន្ត្រីសាធារណរដ្ឋនិយាយថា ខ្មែរប្រមាណ៥ម៉ឺននាក់មករស់នៅឡុងប៊ិចនេះ ដែលជាចំនួនលើសគេបង្អស់របស់សហគមន៍ច្រើន **តទៅទំព័រទី ១២**

អានក្លួចវេបសាយវត្តត្រៃរតនារាម

បច្ចុប្បន្នគណកម្មាធិការនាយកថ្មីរបស់វត្តត្រៃរតនារាម

១-សាន ប៊ុន ប្រធាន
២-ស ឆែល លេខាធិការ
៣-អ្នកស្រី វិយ៉ាដា ហុងទិត លេខាធិការ
៤-ដារារិទ្ធ អ៊ឹង ហិរញ្ញិក
៥-សម្បត្តិ ហ្វើណែល សមាជិក
៦-សម្បត្តិ កែវ សមាជិក
៧-រីដា អេង សមាជិក
៨-រិទ្ធី អ៊ុង សមាជិក
៩-វ៉ាន តាណា វ៉ែន សមាជិក
១០-កុសល នាគ សមាជិក
១១-សំអឿន សេង សមាជិក
១២-អ្នកស្រី ចាន់វន ម៉ុមសមាជិក

(នៅចន្លោះម្នាក់ទៀតដែលពុំទាន់ឃើញមានតែងតាំង)

គណកម្មាធិការអាចារ្យវត្ត

ផាន់ មន - សារឿន ធូ- ឱម ដូ-សម្បត្តិ ហួត-លៀង ម៉ុម

គណកម្មាធិការយាយជីវត្ត

គិម ឡេង ពុធ-ហួត រស់-សុខុម អ៊ុង

គណកម្មាធិការព្រះសង្ឃ

ព្រះតេជគុណ សារិន សែម ចៅអធិការ
ព្រះតេជគុណ ឈីវ នាថ ហូវ គ្រូសូត្រស្តាំ
ព្រះតេជគុណ ប៉ាវ ប៉ាក់ គ្រូសូត្រឆ្វេង
ព្រះតេជគុណ គិម សឿម ង៉ែត សមាជិក

KHMER POST USA, LLC
East Coast Publication

Pin Samkhon,
Publisher & Editor-in-Chief
Email: pinsamkhon@gmail.com
Staff Writers: **Loeum Im,**
Audria Chea,

Contributed Writers:
Mam Yin, Kim Phien,
Lanica Angpak, &
KhmerPostLowell@gmail.com

Soben Pin
Marketing Director
KhmerPostUSA@gmail.com
267-253-3947
Sam Khoeun
Sales Consultant
(781) 244-0522

Design Staffs:
Leang Heng & Mong Meng

KhmerPost USA, LLC is an independent newpaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local, community, and national news; and give an insight into Cambodia & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Pennsylvanian & Massachusett.

Semimonthly edition subscription is available within the U.S. & Canada at $60.00 and 70 Euros in Europe per year. Money order or check is accepted and made payable to:
KhmerPost USA, LLC
438 LINDLEY AVE.
Philadelphia, PA 19120

The Khmer Post has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

ពេទ្យធ្មេញសំរាប់គ្រួសារ Caring Dental For ALL Ages

COMPLETE ផ្តល់គ្រប់សេវាកម្ម
Services

- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ជំងឺចញ្រ្កាញធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អ៊ិនស៊ូរិន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

Convenient
LOCATION
Next to Bank of America on Chelmsford Street

FREE
Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 10/30/11

"EXCLUSIVE OFFER"
$55.00
Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 10/30/11

យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្បាញ៉ុល និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនាថ្ងៃនេះ

724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles-Dental.com

KCDSC
" Empowering People and Communities "
6055 N 5th Street Philadelphia, PA 19120
Chantha Kan — Housing Developer
Tel. 215-276-8830 ext. 30

BIG SALE



2434 S. 16th Street
Philadelphia, PA 19145
4 beds 1.5 bath (all new)
Sale $210,000

338 S. Snyder Avenue
Philadelphia, PA 19148
3 beds 1 bath (all new)
Sale $169,500

7943 Woolston Avenue
Philadelphia, PA 19150
3 beds 1.5 bath (all new)
Sale $155,000

- New Kitchens
- Granite Countertops
- Hardwood floors
- Finished Basement

**If you buy any of these properties, you will qualify for 6% seller assistance, $3,000 from PHFA for first-time homebuyers, and 1.5% transfer tax from Korean Community Development Services Center, which goes towards your closing costs. You can own the home of your dreams!!*

តមកទំព័រទី ១

ខ្យល់ព្យុះអាយរីនបោកបក់...

ការភ័យព្រួយដល់ពលរដ្ឋ និងអ្នកគ្រប់គ្រងយ៉ាងក្រៃលែង ។ ក្នុងពេលយើងកំពុងសរសេរនេះ (ថ្ងៃសៅរ៍ម៉ោង ៩ យប់) ខ្យល់ព្យុះបានបក់មកដល់ "ខេបមេដ" រដ្ឋធានីវ៉ាស៊ីនតុន និងដែនដីញូជើស៊ី ហើយវិទ្យុ ទូរទស្សន៍ បានផ្តល់ព័ត៌មានឱ្យប្រជាពលរដ្ឋចាកចេញពីតំបន់សមុទ្រ ដូចជា ក្រុងញូយ៉ក ក្រុងអាត់ឡង់ទិកស៊ីទី ដែលជាក្រុងកាស៊ីណូដ៏ធំបង្អស់នៅឆ្នេរខាងកើត ។ ប្រជាពលរដ្ឋរាប់ពាន់នាក់បានចាកចេញធ្វើដំណើរទៅរកតំបន់សុវត្ថិភាព អភិបាលរដ្ឋឬចៅហ្វាយក្រុងប្រកាសភាពអាសន្នច្រើនដងដើម្បីអញ្ជើញ ពលរដ្ឋឱ្យប្រ-ញាប់ចាកចេញពីផ្ទះមាត់សមុទ្ររបស់ខ្លួន ។ នៅរដ្ឋផេនស៊ីវេនាមានកំណើតខ្យល់គួចកំណាចមួយទៀត នៅល្ងាចថ្ងៃសៅរ៍កំពុងតែបំផ្លាញផ្ទះសម្បែងអស់ ១៥-១៦ខ្នង រួចហើយទឹកជំនន់ ទឹកភ្លៀងក៏កំពុងឡើងមុំ "ដែលវ៉ែ" ភ្លើងអគ្គិសនីហ្វីឡាខាងជើងឈៀងខាងកើតដាច់ជាច្រើនអន្លើ ។

នៅពុំទាន់មានទទួលសេចក្តីរាយការណ៍ពីការខូចខាតដោយសារខ្យល់ព្យុះអាយរីននៅឡើយ តែគេនៅចាំថា ខែសីហា ឆ្នាំ២០១១ នេះភូមិភាគខាងកើតបានទទួលរងគ្រោះបាតុភូតធម្មជាតិបីដង គឺអាកាសធាតុក្តៅលើស១០០ អង្សា កាលដើមខែ រញ្ជួយផែនដីកាលពីកណ្តាលខែសីហានេះ ចុងបង្អស់ខ្យល់ព្យុះ ។

បន្ថែមចំណុចពីរ : ខ្យល់ព្យុះនេះធ្វើឱ្យមនុស្ស៣៥ស្លាប់ដំណឹងចុងក្រោយ ៕



48-hour formation potential: ☐ Low <30% ▨ Medium 30-50% ▨ High >50%

ក្រុមហ៊ុន ទេសចរណ៍
CENTURY TRAVEL & SERVICE CENTER

904 South 8th Street. Philadelphia, PA 19147
Tel : 215-625-2889; Fax : 215-625-9395
Cell : 267-934-9888; Email : centuryphl@yahoo.com

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុង និងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

- Serve all Airlines
- Domestic & Intl. flights
- Tour Arrangements
- Passport Extension
- Khmer Laissez- Passer
- Immigration
- Tourist Visa
- Notary Public

OFFICE Hours :
Mon - Sat 10:00 A.M - 6:00 P.M
Sun : 12:00 P.M - 5:00 P.M

We Speak Khmer, Chinese, Vietnamese
យើងនិយាយភាសាខ្មែរ_ភាសាចិន_វៀតណាម

APE TEK COMPUTERS

6263 Bustleton ave, Philadelphia PA, 19149 267-672-8898
5709 N 5th Street, Philadelphia PA, 19120 215-276-700

COMPUTER REAPIR

-Virus Removal
-POP-UP & Spyware
-Data Transfer/Backup
-Laptop Screen
-Wireless & Network
-Computer Upgrade



IBM T42, P4, 512 MB, 40GB, DVD PLAYER
Special $249.00

LAPTOP/DESKTOP/CUSTOM BUILD

Sell New & Used Computer & Custom Build High End & Gaming System

P4, 512 MB, 40GB HHD, DVD PLAYER
SPECIAL $99.00

SECURITY CAMERA

Sale and setup Security Camera for Home and Business/Remote View & Night Vision

ជំនាញការខាងជួសជុលកុំព្យូទ័រ
លក់គ្រឿងកុំព្យូទ័រ
និងដាក់គ្រឿងថតវីដេអូ
សំរាប់ការពារសន្តិសុខ

WWW.APETEKCOMPUTERS.COM

4 Camera System—$649.00
8 Camera System—$1200.00
1TB HD, Night Vision, Remote Viewing, Motion Detect...

រញ្ជួយដីនៅច្រាំងខាងកើត

ដោយ : ខ្មែរប៉ុស្តិ៍

●ផែនដីបានផ្ដើមរញ្ជួយយ៉ាងរន្ថើននៅហ្វីឡាដែលហ្វៀ នាវេលាម៉ោង៣រសៀលនៃថ្ងៃអង្គារទី២៣ សីហា នេះ ។ នេះជាលើកដំបូងបង្អស់ដែលហ្វីឡាដែលហ្វៀមានបាតុភូតរញ្ជួយផែនដីនេះស្ទើរធ្វើឱ្យប្រជាពលរដ្ឋជឿមិនបានប្រសិនបើគ្រប់ប្រព័ន្ធផ្សព្វផ្សាយពុំបានបញ្ជាក់ពីព្រឹត្តិការណ៍ដ៏ថ្មីបំផុតនៅឆ្នេរខាងកើតនេះទេ ។

ផែនដីបានផ្ដើមរញ្ជួយពីតំបន់រដ្ឋធានីវ៉ាស៊ីនតុន ហើយរាលដាលដល់ហ្វីឡាដែលហ្វៀ ហើយបន្តយ៉ាងលឿនដល់ទីក្រុងញូយ៉កក្នុងកម្លាំង៥.៨ តែប៉ុន្មានវិនាទីយ៉ាងខ្លីភាពរញ្ជួយក៏ស្ងប់ស្ងាត់ទៅវិញ។ នៅអាគារសាធារណៈជាច្រើន នាតំបន់ទាំងប៉ុន្មានខាងលើ ក៏បានត្រូវបញ្ជាឱ្យជន្លៀសខ្លួនចេញពីអាគារធំៗទាំងនោះ ជាបន្ទាន់ដែរ ដើម្បីការពារសុវត្ថិភាព។

ភ្លាមៗបន្ទាប់ពីភាពរញ្ជួយបានបញ្ចប់ទៅ ទោះជាមានការវិភាគខ្លះ ស្ដីពីប្រភពធម្មជាតិនៃមណ្ឌលផ្ដើមរញ្ជួយក្ដី អ្នកតាមដានមួយចំនួនមិនចោលទស្សនៈថា អាចនឹងមានការសាកល្បងគ្រាប់បែកបរមាណូនៅក្នុងដីនៅកន្លែងសម្ងាត់ណាមួយជាមិនខាន ៕

តមកទំព័រទី ១ បុណ្យអុំទូកនៅហ្វីឡាដែលហ្វៀ...

កីឡាករអ្នកអុំចំនួន១០០នាក់ ការប្រណាំងទូតនឹងប្រព្រឹត្តទៅនៅទន្លេនា"ផឹមឡេនឌីង" ក្រោមការតាមដានសុវត្ថិភាពយ៉ាងគ្រប់គ្រាន់ ។

ពាណិជ្ជករកំពុងចុះឈ្មោះបន្តបន្ទាប់ចូលមកបង្ហាញផលិតផលរបស់ខ្លួន ដែលអ្នកមកទស្សនាអុំទូកអាចភ្លក់រស់ជាតិម្ហូបខ្មែរ-ឡាវ-ថៃញ ឬហ្វីលីពីនយ៉ាងប្លែកមាត់ជាមួយក្រុមគ្រួសារបាន ។

ថវិកាគាំទ្របានមកពីវត្តព្រះពុទ្ធរង្សី ពីផ្សារស្រ្តីងគ្នាឌិន "ពីកាស៊ីណូសូគ័រហោវ" ពីក្រុមហ៊ុន "ធារាវ៉ាប៉រងណោសិនវ៉ាយ" រីឯកម្មវិធីកំដរភ្ញៀវនៅលើឆាកមានជាអាទិ៍ការ សូត្រមន្តជូនពរសព្វសាធុកាដល់ភ្ញៀវ-មានរបាំបុរាណខ្មែរជូនពរ-សុវណ្ណមច្ឆា-នារីជាជួរ មានការបង្ហាញរបាំ ទំនៀមទំលាបឡាវ-ការបង្ហាញរបស់ក្រុមនិស្សិតប៊ូថាន ចូលរួមដោយក្រុមភ្លេងសម័យច្រើនក្រុម ក្រុមចំរៀងហីបហប ឬក្រុមរបាំប្រែកដិនរបស់យុវជនសម័យច្រើនក្រុមផង។

កម្មវិធីដែលនឹងផ្ដើមនៅម៉ោង១១ព្រឹកថ្ងៃសៅរ៍ ទី៩កញ្ញាឆ្នាំ២០១១នឹងបញ្ចប់ទៅវិញនៅម៉ោង៥ល្ងាច ដោយការប្រកាសផ្ដល់ពានរង្វាន់ដល់ជ័យលាភីអុំទូក ៕ **ដោយ : ខ្មែរប៉ុស្តិ៍**

Business for sale
Lowell City Video

Lowell City Video 32-38 Branch St., Unit #5,
Lowell, MA 01851



For more information contact:
Ms. Sokha 978.452.4500 or 978.996.6921

បុណ្យពុទ្ធាភិសេកនៅវត្តព្រះពុទ្ធរង្សី

ដោយ : អ៊ុម ឈឿម

បើគេធ្វើដំណើរកាត់តាមផ្លូវលេខ៦មកដល់ផ្លូវ Ritner នាតំបន់ហ្វីឡាដែលហ្វៀខាងត្បូង គេនឹងបានឃើញអារាមពុទ្ធសាសនាដ៏ប្រណិតមួយដែលមានរចនាបថបែបបុរាណ និងរំលេចដោយក្បាច់ក្បូរដ៏ល្អប្រណិត ដែលញ៉ាំងឱ្យមានការជាប់ចិត្តជិតអារម្មណ៍ពីសំណាក់អ្នកផងទាំងពួង ដែលធ្វើដំណើរកាត់ ។ ពិសេសជាងនេះព្រះពុទ្ធអង្គកំពុងគង់ព្រះពៃ្ទន និងមានទំហំយ៉ាងធំ ដែលវិចិត្រករចំណាយពេលវេលាជិត២ឆ្នាំក្នុងការរចនានោះ ក៏ជាផ្ទាំងស៊ីបមួយដ៏សំខាន់ក្នុងការដាស់អារម្មណ៍ដល់បណ្ដាអ្នកឆ្លងកាត់គ្រប់ជាតិសាសន៍ឱ្យគយគន់ស្ទើរមិនចង់ដាក់ភ្នែក ។

នេះជាវត្ត "ព្រះពុទ្ធរង្សី" ដែលជាវត្តដ៏ប្រណិត និងលេចធ្លោរជាងគេក្នុងចំណោមវត្តខ្មែរទាំងបួនក្នុងទីក្រុងហ្វីឡាដែលហ្វៀ ហើយកាលពីថ្ងៃសៅរ៍-អាទិត្យ ទី២១-២២ ខែសីហា កន្លងមកនេះ វត្តដែលមានអាយុកាលទើបបាន៨ឆ្នាំនេះបានប្រារព្ធធ្វើពិធីបុណ្យសាសនាមួយឈ្មោះថា "ពុទ្ធាភិសេក" ដែលជាពិធីឆ្លងផ្ទាំងគំនូរព្រះពុទ្ធរូបដ៏ធំមួយដូចយើងបានរៀបរាប់ខាងលើ ។

កម្មវិធីបុណ្យមានសភាពយ៉ាងល្អរលូន និងប្រកបដោយបរិយាកាសសប្បាយរីករាយដោយមានពុទ្ធបរិស័ទ និងភ្ញៀវកិត្តិយសយ៉ាងច្រើនកុះករ ។ ទាក់ទងនឹងការវិវឌ្ឍន៍របស់វត្ត "ព្រះពុទ្ធរង្សី" នេះ យើងនឹងព្យាយាមសុំការអនុញ្ញាតដើម្បីធ្វើកិច្ចសម្ភាសន៍ពីសំណាក់ព្រះគ្រូចៅអធិការ ហើយធ្វើការចុះផ្សាយនៅពេលក្រោយទៀត ៕

តមកទំព័រទី ៤ កឹម សុខា : ហ្វីឡាដែលហ្វៀនៅតែ...

ឱ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋនៅតាមចុងកាត់មាត់ញក និងតាមស្រុកស្រែចំការជាដើម ។

លោក សុខា បានថ្លែងពីប្រទេសកម្ពុជាក្នុងខណៈដែលលោកកំពុងមានបេសកកម្មនៅឯខេត្តបាត់ដំបងដោយគ្មានសំចៃមាត់ថា : បច្ចុប្បន្នគណបក្សប្រជាជនកម្ពុជាកំពុងតែទទួលនូវបរាជ័យ និងទទួលរងនូវភាពអាម៉ាស់ជាច្រើនករណី ឧទាហរណ៍ដូចជាពុំមានលទ្ធិភាពគ្រប់គ្រាន់ក្នុងការការពារព្រៃឈើ.ឡូតិ៍នេសាទ និងការបណ្ដេញប្រជាពលរដ្ឋស្លូតត្រង់ចេញពីតំបន់បឹងកក់ពីសំណាក់អាជ្ញាធរសមត្ថកិច្ចដែលនៅក្រោមបញ្ជាក្រុមហ៊ុនឯកជនដ៏ធំមួយ ដែលស្និទ្ធជាមួយ ហ៊ុន សែន រហូតទាល់តែមានការកាត់ផ្ដាច់នូវប្រាក់កម្ចីជាច្រើនរយលានដុល្លារពីសំណាក់ធនាគារពិភពលោកជាដើម...។ល។

ដោយឡែកលោក សុខា បានបន្តសំពងដល់គណបក្ស សម រង្ស៊ី ដែលជាអតិតដៃគូរសម្ព័ន្ធភាពរបស់ខ្លួន ដោយបញ្ចេញឈ្មោះចំៗថា: "បច្ចុប្បន្នគណបក្ស សម រង្ស៊ី កាត់តែមានការថមថយនូវចំនួនអ្នកគាំទ្រយ៉ាងច្រើន ព្រោះដោយសារបក្សមួយនេះកំពុងតែមានវិបត្តិផ្ទៃក្នុងដែលជាហេតុនាំឱ្យគ្មានពេលវេលាគ្រប់គ្រាន់សម្រាប់ចុះតាមមូលដ្ឋានដែលសមាជិកសមាជិការបស់គណបក្ស សម រង្ស៊ី នៅតាមបណ្ដាខេត្ត-ក្រុងមួយចំនួន នឹងត្រៀមខ្លួនចូលរួមជាមួយគណបក្សសិទ្ធិមនុស្សខាងមុខនេះហើយ ។

ក្នុងកិច្ចប្រជុំតាមទូរស័ព្ទនាពេលនោះ លោក សុខា បានប្រាប់ដល់បណ្ដាអ្នកគាំទ្ររបស់ខ្លួនគ្រប់បណ្ដារដ្ឋនានាទូទាំងសហរដ្ឋអាមេរិកថា : បច្ចុប្បន្នទីក្រុងហ្វីឡាដែលហ្វៀ នៅតែជាទីក្រុងដ៏ឆ្នើម និងជាទីក្រុងគំរូមួយរបស់សាខាគណបក្សសិទ្ធិមនុស្សទូទាំងពិភពលោកតែម្ដង ព្រោះទីក្រុងនេះមានសកម្មជនគាំទ្រច្រើន និងសកម្មជាងបណ្ដារដ្ឋ ឬប្រទេសណាៗទាំងអស់ ។ ប្រធានបក្សរូបនេះបន្តថា : សកម្មជននៅហ្វីឡាដែលហ្វៀ មើលទៅហាក់មានជីវភាពពុំសូវធូរធារប៉ុន្មានឡើយ ប៉ុន្តែពួកគាត់នៅតែសកម្ម និងមិនរួញរាក្នុងការជួយជ្រោមជ្រែងដល់គណបក្សសិទ្ធិមនុស្សឡើយ ថ្នាក់ដឹកនាំសាខាគណបក្សសិទ្ធិមនុស្សប្រចាំទីក្រុងហ្វីឡាដែលហ្វៀ ប្រធានបក្សថ្មី គឺលោក វ៉ា សាម៉ុន អតីតសកម្មជនរបស់គណបក្សហ្វ៊ុនស៊ិនប៉ិចហាក់រីកមុខមិនតិចឡើយ ចំពោះការវិវឌ្ឍន៍ទៅមុខរបស់សាខាបក្សនៅទីក្រុងហ្វីឡាដែលហ្វៀនេះ ៕

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសែតអង់គ្លេស
អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី
ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី២៦ ខែសីហា ឆ្នាំ២០១១

អាកាសចរណ៍ជាតិនឹងចាប់ផ្តើមហោះហើររវាងខេត្តសៀមរាប និងខេត្តព្រះសីហនុ

ដោយ : SIMON MARKS

THE CAMBODIA DAILY

● មន្ត្រីមួយរូបនៅទីស្តីការគណៈរដ្ឋមន្ត្រីបានមានប្រសាសន៍កាលពីម្សិលមិញថា ក្រុមហ៊ុនអាកាសចរណ៍ Cambodia Angkor Air នឹងចាប់ផ្តើមសេវាហោះហើរជាប្រចាំរវាងខេត្តសៀមរាប និងខេត្តព្រះសីហនុត្រឹមដំណាច់ឆ្នាំនេះ ។

មិនមានជើងហោះហើរទៅកាន់ខេត្តព្រះសីហនុ ដែលជារមណីយដ្ឋានឆ្នេរសមុទ្រដ៏ល្អរបស់ប្រទេសកម្ពុជានោះទេ ទោះបីជាអាកាសយានដ្ឋាននៅទីនោះត្រូវបានកែលម្អឱ្យមានស្តង់ដារអន្តរជាតិកាលពីពាក់កណ្តាលឆ្នាំ២០០៩ ហើយវិស័យឯកជនក៏បានជំរុញយ៉ាងខ្លាំងឱ្យក្រុមហ៊ុន Cambodia Angkor Air នេះចាប់ផ្តើមការហោះហើរទៀងទាត់ទៅកាន់តំបន់ឆ្នេរនេះ ដើម្បីបង្កើនទេសចរណ៍ក៏ដោយ ។

លោក តឹករ៉េត សំរេច ជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ដែលត្រូវបានចាត់តាំងដោយរដ្ឋាភិបាលឱ្យជួយបង្កើតអាកាសចរណ៍ជាតិនេះ បានមានប្រសាសន៍ថា Angkor Air ដែលជាការវិនិយោគរួមគ្នារវាងក្រុមហ៊ុនអាកាសចរណ៍វៀតណាម និងរដ្ឋាភិបាលនោះបានសម្រេចធ្វើការហោះហើរទៅខេត្ត

តទៅទំព័រទី២២

National Carrier to Start Siem Reap-S'ville Flights

By Simon Marks
THE CAMBODIA DAILY

Cambodia Angkor Air will launch a regular flight service between Siem Reap and Sihanoukville by the end of the year, an official at the Council of Ministers said yesterday.

There are currently no flights to Sihanoukville, the country's premier coastal resort, even though the airport there was upgraded to international standards in mid-2009 and the private sector has pushed hard for Angkor Air to start scheduled flights to the coast to boost tourism.

Council of Ministers Secretary of State Tekreth Samrach, who was appointed by the government to help set up the national carrier, said that Angkor Air—a joint venture with Vietnam Airlines and the government—had made the decision to fly to Sihanoukville on the back of growing tourist arrivals to Cambodia.

The total number of visitors arriving by air in Cambodia increased by 13.4 percent to 1.4 million people in the first six months of the year.

"We have to start to do something, because this year the number of tourists still increase," said Mr Samrach. "Two years ago, we were not sure because of economic difficulties."

"Around November is possible. We want to have a flight as soon as possible," he said, adding that the national carrier would add an Airbus 321 to its current fleet of aircraft—one Airbus 321 and two

Continued on page 9

សមាជិកជាន់ខ្ពស់នៃអង្គចៅក្រមចំនួន១៩រូបបានទទួលការពន្យារអាណត្តិ

ដោយ : គុច ណារ៉េន

THE CAMBODIA DAILY

យោងតាមព្រះរាជក្រឹត្យមួយបានឱ្យដឹងថា សមាជិកជាន់ខ្ពស់នៃអង្គចៅក្រមចំនួន១៩រូបរួមទាំងលោក ឌិត មុន្ទី ដែលជាប្រធានតុលាការកំពូលផងនោះ បានទទួលការពន្យារអាណត្តិដែលអនុញ្ញាតឱ្យអ្នកទាំងនោះបន្តការងារ បើទោះបីជាឈានដល់អាយុ៦០ឆ្នាំ ដែលច្បាប់តម្រូវឱ្យចូលនិវត្តន៍ក៏ដោយ ។

ព្រះរាជក្រឹត្យចុះកាលបរិច្ឆេទថ្ងៃទី២៥ ខែកក្កដា នឹងដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រនរោត្តម សីហមុនី នេះមិនបានបញ្ជាក់ពីមូលហេតុនៃការពន្យារអាណត្តិនេះទេ ។

នៅក្នុងចំណោមអ្នកដែលត្រូវបានអនុញ្ញាតឱ្យរក្សាតំណែងរបស់ខ្លួន រួមមានចៅក្រម ឌិត មុន្ទី និងអនុប្រធានរបស់លោកនៅតុលាការកំពូលគឺលោក ឃឹម ប៉ុណ្ណ លោក ជីវ កេង ជាប្រធានសាលាដំបូងរាជធានីភ្នំពេញ លោក ថោង អុល ជាប្រធានសាលាដំបូងខេត្តពោធិ៍សាត់ លោក ខ្លូត ពេជ្រ ជាប្រធានសាលាខេត្តកំពង់ស្ពឺ និងលោក ទិត សុទ្ធី ជាប្រធានសាលាដំបូងខេត្តកំពង់ចាម ។

នេះគឺជាការពន្យារអាណត្តិម្តងទៀតសម្រាប់ចៅក្រម ឌិត មុន្ទី

តទៅទំព័រទី១៩

Retirement Reprieve for 19 Court Mem

By Kuch Naren
THE CAMBODIA DAILY

Nineteen senior members of the judiciary—including Supreme Court President Dith Munty—have been granted an extension allowing them to continue work despite having reached the legal retirement age of 60, according to a Royal decree.

The decree, dated July 25, and signed by King Norodom Sihamoni, does not stipulate a reason for the extension. Among those permitted to retain their position are Judge Munty and his deputy at the Supreme Court, Khim Phonn; Phnom Penh Municipal Court President Chiv Keng; and Thong Ol, Khlaut Pich and Dith Sothy, who are presidents of the Pursat, Kompong Speu and Kompong Cham provincial courts, respectively. This is a repeat extension for Judge Munty, who turned 60 in November 2009.

A second decree also lists nine judges and prosecutors who will be retired this year. In that decree, Ith Rady is ordered to retire from his post as a judge at the Ministry of Justice but is permitted to keep his position as secretary of state.

The decree came after a July 19 Supreme Council of Magistracy meeting in which 55 municipal and provincial court judges were assigned new positions as part of a nationwide judiciary rotation plan, said Judge Pich, president of Kompong Speu Provincial Court, who turned 60 in February.

"It's lucky for me to get an extension and not have to retire, even though I am 60 years old. It will let me finish some work that I have done about 50 percent of," he said, adding that extensions are typically valid for one year.

Continued on page 22

អ្នកស្លាប់ និងរងរបួសដោយសារស្រាសកើនដល់៣០នាក់ហើយ

ដោយ : ផល សុខភារី

THE CAMBODIA DAILY

ក្រុមមន្ត្រីខេត្តបាននិយាយកាលពីម្សិលមិញថា មនុស្សចំនួន៦នាក់បានស្លាប់ និង២៤នាក់សម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ដោយសារផឹកស្រាសពុលនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ក្នុងរយៈពេលមួយសប្តាហ៍ចុងក្រោយនេះ ។

លោក យូ យីនទី ព្រះរាជអាជ្ញារងសាលាដំបូងខេត្តបានថ្លែងថា នគរបាលខេត្តបានចាប់ខ្លួនឈ្មោះ ម៉ុត ចំណាប់ អាយុ៤៩ឆ្នាំ ដែលតាមការសង្ស័យថា បានលក់ស្រាដែលបំពុលក្រុមអ្នកភូមិ ។ លោក យីន នី ក៏បានមានប្រសាសន៍ផងដែរថា នគរបាលបានរកឃើញថ្នាំសម្លាប់ស្មៅមួយកញ្ចប់នៅក្នុងជនសង្ស័យ ។

លោក យីន នី បានមានប្រសាសន៍ថា "ខ្ញុំបានទៅសួរអ្នកចែកចាយស្រាសដ៏ធំនៅវាលវែង ជាទីដែលជនសង្ស័យបានទិញស្រាសរបស់គាត់ ។ ពួកគេបាននិយាយថា

តទៅទំព័រទី១៩

Casualties From Contaminated Rice Wine Rise to 30 in Pursat

Police found weed killer in suspect's house

By Phal Sokpheary
THE CAMBODIA DAILY

Six people have now died and 24 have been hospitalized from drinking contaminated rice wine in Pursat province's Veal Veng district in the past week, provincial officials said yesterday.

Provincial deputy prosecutor Yo Yeu Ny said that provincial police have arrested Mot Chamnab, 49, on suspicion of selling the wine that poisoned the villagers. Mr Yeu Ny also said that police found a package of weed killer in the suspect's house.

"I went and asked the main distributor of rice wine [in Veal Veng] where [the suspect] had bought his rice wine. They said that they had sold him 15 liters," Mr Yeu Ny said. "But we know that 30 liters of wine was sold to the [poisoned] people, so at this point, it should be investigated where the other 15 liters came from."

continued on page 9

ក្រុមអ្នកភូមិមកធ្វើការតវ៉ាពីជម្លោះដីធ្លីនៅសួនសេរីភាព

ដោយ : ភោគ ដន

THE CAMBODIA DAILY

ក្រុមអ្នកភូមិចំនួនជាង៥០០នាក់ មកពីខេត្តកណ្តាល និងខេត្តកំពង់ចាម បានធ្វើការតវ៉ានៅសួនសេរីភាពនាទីក្រុងភ្នំពេញកាលពីម្សិលមិញ អំពីវិវាទដីធ្លីពីរផ្សេងគ្នាដែលធ្វើឱ្យប៉ះពាល់ដល់ពួកគាត់ ។

ប្រជាពលរដ្ឋចំនួនជាង៤០០នាក់ មកពីស្រុកចំការលើខេត្តកំពង់ចាមបានឱ្យដឹងថា ពួកគាត់ធ្វើការតវ៉ា ពីព្រោះកាលពីខែកក្កដា លោកមេឃុំបុសខ្នុរបាននិយាយថា ពួកគាត់នឹងត្រូវចាកចេញពីដីរបស់ខ្លួន ដើម្បីយកដីរបស់ពួកគាត់អភិវឌ្ឍ ។

ឈ្មោះ សុន ទូច ជាអ្នកភូមិម្នាក់មកពីឃុំបុសខ្នុរបាននិយាយថា "ពួកគេនិយាយប្រាប់យើងថា ពួកគេចង់អភិវឌ្ឍដីរបស់យើងហើយថា យើងនឹងត្រូវរើទៅដីថ្មី ប៉ុន្តែយើងមិនដឹងថា តើពួកគេនឹងអភិវឌ្ឍអ្វីទេ ឬថា

តទៅទំព័រទី ១១

Two Land Dispute Protests in Freedom Park

By Phok Dorn
THE CAMBODIA DAILY

More than 500 villagers from Kandal and Kompong Cham provinces protested in Phnom Penh's Freedom Park yesterday over two separate land disputes affecting them.

More than 400 people from Kompong Cham's Chamkar Loeu district said they were protesting because in July, their Bos Khnor commune chief said they would have to leave their land so it could be developed.

"They tell us they want to develop our land and that we will move to new land, but we don't know what they are developing or where we are moving," said Sonn Tuch, a villager from Bos Khnor.

Yous Phoem, also from Bos Khnor, said the villagers had come to Freedom Park because, "We knew that this was a place to express opinions and find justice."

Commune chief Kim Khon said yesterday that the land the villagers lived on was state land and had been given to a rubber company.

"The villagers are afraid of the authorities in their provinces," said Chan Soveth, program officer for Adhoc's monitoring section. "They have come to Freedom Park because this is their last resort. They will keep coming here until they have a solution."

In a separate dispute, 72 villagers from Kandal province protested yesterday because a former local official has been clearing 23 hectares of land where 114 families have been living since 1979.

In July 2010, Kandal Provincial Court awarded the land to Prak Savuth, former deputy governor of Kien Svay district, after a land own-

continued on page 9

Flights...

CONTINUED FROM PAGE 8

ATR 72s—in November.

Angkor Air is primarily looking into flights between Siem Reap and Sihanoukville, but the airline has not written off the possibility of starting a connection between Sihanoukville and Phnom Penh, he said.

Vann Chan Ty, deputy financial manager at Angkor Air, declined to comment, referring all questions to the State Secretariat of Civil Aviation.

Soy Sokhan, undersecretary of state at the SSCA, confirmed that Angkor Air was on track to start flights between Siem Reap and Sihanoukville, but declined to provide details.

Earlier this month, officials from the Ministry of Tourism, Cambodia Angkor Air and Societe Concessionnaire des Aeroports, the national airport operator, held a meeting during which the airline announced its interest in starting flights to Sihanoukville, according to a participant at the meeting.

have been frustrated by the lack of urgency in bringing scheduled flights to Sihanoukville. Many believe the city will only develop into a globally recognized coastal destination once tourists start to arrive by air.

Analysts say that there is a market to support regular flights to Sihanoukville.

According to a report published in January by Frederick Thomas, an economist at the International Finance Corporation, the World Bank's private sector branch, the number of tourists visiting Siem Reap and Sihanoukville during their stay in Cambodia justifies starting regular flights between the two destinations.

The report said that of the more than 150,000 international tourists visiting Sihanoukville every year, 33.2 percent were likely to go to Siem Reap as well. It predicted the number of people flying per week between Sihanoukville and Siem Reap would range from 161 to 319, depending on the season.

"When we have regular scheduled flights out, travel agencies will make new pitches," said Luu Meng, president of the Cambodia Hotel Association, adding that an air route between Sihanoukville and Siem Reap would also open up cargo opportunities for transporting fresh seafood from Cambodia's coastline.

Currently, many of the hotels in Siem Reap import seafood from Thailand, Malaysia and Vietnam.

Mr Meng said that flights into Sihanoukville would also open markets for tourists to places like Kep and Kampot provinces, both of which are not far from Sihanoukville International Airport.

"Everyone is well prepared," he said. "They're just waiting for flights to start."

Casualties From...

Continued from page 8

Mr Yeu Ny said that there was no other store in Veal Veng that sold rice wine in such large quantities.

Police sent samples of the deadly rice wine for testing at the provincial health bureau on Monday, but Meas Bot, deputy provincial police chief, said that no results were yet available to his investigation.

Mr Bot said that the latest casualty figures—up from 5 dead and nine hospitalized on Monday—had been confirmed with the provincial hospital.

"They were not all part of the same group," Mr Bot said. "Some people drank it on different days and have not died; they were just poisoned and are now in hospital."

Sok Sitha, deputy police chief of Veal Veng district, said all victims had experienced the same side effects from drinking the wine—vomiting, loss of vision and severe stomach pain.

Mr Sitha also said that most of the victims were not locals, but migrant workers from other provinces who had come to Veal Veng to find temporary work in local industries such as farming.

Two Land Dispute...

Continued from page 8

ership dispute with villagers had dragged on since the early 1990s.

"We won't have any land to grow our rice in the rainy season," said Choem Sarun, a villager from Samraong Thom commune. She added that villagers had been threatened with arrest by authorities.

Local families were each offered $250 by Mr Savuth for their land, but were not given any new land to live on, villagers said.

"We want Prime Minister Hun Sen to know we want our land and we are afraid every day," Ms Sarun said.

Kandal provincial governor Heng Hiem denied police had threatened villagers involved in the dispute.

តមកទំព័រទី ១៥

ព្រះសង្ឃត្រូវបានបណ្តេញ...

ការបណ្តេញចេញនេះគឺមកពីហេតុផលនយោបាយ ។

ព្រះតេជគុណ សាវ៉ាត បានមានសង្ឃដីកាថា "អាត្មាត្រូវបានប្រជាជននិមន្តទៅសូត្រមន្ត។ អាត្មាពុំបានធ្វើអ្វីមួយឱ្យខូចឈ្មោះព្រះសង្ឃឡើយ" ។

នេះមិនមែនជាលើកដំបូងទេ ដែលព្រះតេជគុណ សាវ៉ាត ត្រូវបានដាក់ទោសដោយមន្ត្រីសង្ឃ។ កាលពីដើមឆ្នាំនេះ ព្រះអង្គត្រូវបានបណ្តេញចេញមិនឱ្យគង់នៅក្នុងវត្តនៅក្នុងក្រុងភ្នំពេញ ពីព្រោះព្រះអង្គបានចូលរួមក្នុងពិធីសូត្រមន្តប្រោះព្រំគ្រួសារប្រជាជននៅបឹងកក់ ។

ព្រះអង្គបានមានសង្ឃដីកាថា "តាមពិតអាត្មាគ្រាន់តែជួយប្រជាពលរដ្ឋប៉ុណ្ណោះ ពីព្រោះព្រះសង្ឃក៏ជាពលរដ្ឋម្នាក់ដែរ" ។

លោក សុខ គឹមសេង ដែលជាក្រុមប្រឹក្សាខេត្តរបស់គណបក្ស សម រង្ស៊ី នៅក្នុងខេត្តសៀមរាប បានថ្លែងថា ការបណ្តេញចេញនេះបានរំលោភសិទ្ធិរបស់ព្រះតេជគុណ សាវ៉ាត ។ "ខ្ញុំបានឃើញរដ្ឋាភិបាលជានិច្ចកាលធ្វើដូច្នេះជាមួយប្រជាជនដែលប្រឆាំងខ្លួនពួកគេចង់បញ្ឈប់ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ" ។

លោកបានមានប្រសាសន៍ថា ព្រះតេជគុណ លួន សាវ៉ាត មិនមែនជាសមាជិករបស់គណបក្ស សម រង្ស៊ី ដូចដែលអាជ្ញាធរខ្លះបានអះអាងនោះទេ ។ "ព្រះសង្ឃផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាអាចពាក់ព័ន្ធក្នុងនយោបាយ និងមានប័ណ្ណសមាជិករបស់គណបក្សប្រជាជនកម្ពុជាទៅទៀត ប៉ុន្តែព្រះតេជគុណ សាវ៉ាត គ្រាន់តែជាសង្ឃតូចតាចប៉ុណ្ណោះ ហើយបែរជាត្រូវដាក់ទោសទៅវិញ" ។

សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត បានមានសង្ឃដីកាកាលពីម្សិលមិញថា ព្រះអង្គមិនដឹងអំពីករណីថ្មីបំផុតនេះទេ ប៉ុន្តែព្រះអង្គដឹងអំពីការពាក់ព័ន្ធរបស់ព្រះតេជគុណ លួន សាវ៉ាត ក្នុងការតវ៉ាផ្សេងៗទៀត។ ព្រះអង្គបានមានសង្ឃដីកាថា "ព្រះសង្ឃគ្មានសិទ្ធិពាក់ព័ន្ធជាមួយនយោបាយឬចូលរួមក្នុងសកម្មភាពកូដកម្ម ឬបំផ្លាញលោកដោយនាំឱ្យប្រជាពលរដ្ឋធ្លាក់ក្នុងបញ្ហានោះទេ" ៕

តមកទំព័រទី ១៥

ជនរត់ពន្ធឈើប្រណិតត្រូវបាន...

ទៅកាន់ទីផ្សាររបស់វៀតណាម" ។

លោក ឡុង វុទ្ធា ជាប្រធាននគរបាលអន្តោប្រវេសន៍ច្រកព្រំដែនអូរយ៉ាដាវបានមានប្រសាសន៍ថា រថយន្តក្រុងដឹកភ្ញៀវទេសចរណ៍មួយគ្រឿងដែលជារបស់ក្រុមហ៊ុន Horng Phat Corporation របស់វៀតណាមត្រូវបានឃាត់ឱ្យឈប់នៅច្រកឆែកឆេរនេះកាលពីល្ងាចថ្ងៃអង្គារ ។

លោកបានមានប្រសាសន៍ថា "រថយន្តក្រុងនេះ ផ្ទុកទេសចរវៀតណាមចំនួន១៤នាក់ ប៉ុន្តែមើលទៅហាក់ដូចជាធ្ងន់ខ្លាំងខុសប្រក្រតី" ដោយលោកបន្ថែមថា ក្រុមមន្ត្រីបានរកឃើញកំណាត់ឈើសាក់នៅខាងក្នុងកាប៊ីនក្រោមកៅអីនៃរថយន្តក្រុងនេះ។ កាលបរិច្ឆេទសម្រាប់ឡើងតុលាការមិនទាន់កំណត់នៅឡើយទេ ៕

ក្រុមហ៊ុនទេសចរណ៍
ភ្នំពេញអន្តរជាតិ
Phnom Penh International Travel Services
21 Branch St., Ste #1 Lowell, MA 01851
Tell: 978-970-5999 Fax: 978-970-5599
109 Lafayette St. #C-5 New York, NY 10001
Tell: 212-219-2299 Fax: 212-219-9930

- លក់សំបុត្រយន្តហោះសម្រាប់ក្នុង និងក្រៅប្រទេស
- ធ្វើលិខិតធានា ប្តី ប្រពន្ធ ឬគូដណ្តឹងពីស្រុកខ្មែរ
- ធ្វើលិខិតសុំច្បាប់ចេញចូល -Re-Entry Permit
- ពន្យា Passport ខ្មែរ Laisser Passer
- ធ្វើទិដ្ឋាការ Visa ទៅអាស៊ី
- ធ្វើលិខិតសុំ Green Card I-94 Work Permit
- បំពេញសុំចូលសញ្ជាតិ
- ថតរូបសម្រាប់ចូលសញ្ជាតិ និងទទួលផ្ញើប្រាក់ទៅស្រុកខ្មែរគ្រប់ប្រទេស
- លក់ Money Order និងបោះត្រា

Nortary Public

ភោជនីយដ្ឋាន ណាម វាង (ភ្នំពេញ)
Nam Vang Restaurant
571 Unit#1 Adams Svenue. Philadelphia, PA 19120
(inside Hong Kong Market) (215) 742-9488



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុក
គ្រប់រសជាតិផ្លែឈើ ដូចជា:
ទុរេន ឬ អាវ៉ូកាដូ ហើយជាពិសេស
មានទឹកអំពៅស្រស់ៗ

១_មុខជំនាញខាងម្ហូបខ្មែរ យ៉ាងចំណាន ដូចជា :
-គុយទាវភ្នំពេញ
-គុយទាវ ឬមី-ខគោ
-មីកន្តាំង ឆារសាច់គោ
-មីកន្តាំងឆារគ្រឿងសមុទ្រ
-បាយឆារគ្រប់មុខ
-សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

២_មុខជំនាញម្ហូបវៀតណាម ល្បីឆ្ងាញ់ ដូចជា :
-នំបញ្ចុកទឹកត្រីពិសេស
-នំប៉័ងបាតេ ឬសាច់គោអាំង
-ខគោ នំប៉័ង ឬ មី និងគុយទាវ
-បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

Open 7 days a week from 9a.m-9p.m
បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច

ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ រ.ជ.រ.ប.ខ លោកតា សឺន សាន

លោក ម៉ម យឺន

ដោយ : ម៉ម យឺន

●●●ជាពិសេសព្រះអង្គបានអំពាវនាវឱ្យប្រជាពលរដ្ឋខ្មែរ ដែលស្រឡាញ់ថ្កាប់មុខលើព្រះអង្គត្រូវតែរត់ចូលព្រៃម៉ាកគីរួមកម្លាំងជាមួយកងទ័ពព្រៃយួនយៀកកុង ដែលកំពុងបញ្ចេញសកម្មភាពវាយប្រយុទ្ធយ៉ាងសាហាវឃោឃៅបំផុតទៅលើកងទ័ពជាតិខ្មែរស្នេហាជាតិក្រោមការដឹកនាំរបស់លោកសេនាប្រមុខ លន់ នល់ និងត្រង់ សិរិមតៈ ។

ទឹកចិត្តកងទ័ពជាតិខ្មែរ ក្រោមបញ្ជាលោក លន នល់

ក្រោយពេលរដ្ឋសភាបានសម្រេចដកអំណាចពីប្រមុខរដ្ឋខ្មែររួចហើយ ហើយសម្រេចធ្វើការទាមទារតវ៉ាឱ្យកងទ័ពព្រៃយួនយៀកកុងដកកងទ័ពចេញពីប្រទេសខ្មែរមកកងទ័ពព្រៃយួនបានទទួលបញ្ជាពីមេដឹកនាំយួនកុម្មុយនីស្តឱ្យវាយប្រហារទៅលើកងទ័ពជាតិខ្មែរភ្លាមដែរ ធ្វើឱ្យទឹកដីខ្មែរ និងបណ្តាខេត្តខ្មែរនៅជាប់ព្រំប្រទល់ដែនត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃត្រួតត្រារបស់កងទ័ពព្រៃយួនទាំងអស់ រួចហើយកៀរប្រជាពលរដ្ឋខ្មែរឱ្យចាកចេញពីភូមិស្រុកទៅនៅក្នុងព្រៃ ដើម្បីបង្ហាត់បង្រៀន និងបញ្ចូលមនោគមវិជ្ជាកុម្មុយនីស្តឱ្យរួមដៃវាយប្រយុទ្ធទៅលើកងទ័ពស្នេហាជាតិខ្មែរវិញ ហើយដណ្តើមអំណាចយកមកថ្វាយប្រមុខរដ្ឋខ្មែរពីមុននោះឱ្យបានក្នុងពេលឆាប់ៗនេះវិញ ។

ចម្បាំងនៅក្នុងស្រុកបានឆាបឆេះយ៉ាងសន្ធោសន្ធៅខ្លាំងឡើង ដោយសារអតីតប្រមុខរដ្ឋបានបញ្ឆេះឡើងសម្រាប់ឱ្យបានអំណាចព្រះអង្គមកវិញ ។

ដោយសារទឹកចិត្តស្នេហាជាតិយ៉ាងមោះមុតរបស់ជនជាតិខ្មែរទាំងប្រទេស ទើបបណ្តាលឱ្យនាំគ្នាចូលទៅរួមសាមគ្គីគ្នាចាប់កាន់អាវុធ វាយប្រយុទ្ធតបតវិញយ៉ាងអង់អាចក្លាហានបួរផ្តាច់បំផុត ដើម្បីការពារឯករាជ្យ សិទ្ធិសេរីភាព និងបូរណភាព អធិបតេយ្យភាពទឹកដីឱ្យបានគង់វង្សតទៅ ។

ប៉ុន្តែទោះបីជាកងទ័ពជាតិ និងប្រជាពលរដ្ឋស្នេហាជាតិខ្មែរទាំងអស់ បានប្រឹងប្រែងប្រយុទ្ធតស៊ូយ៉ាងខ្លាំងក្លាណាក៏ដោយ ក៏កម្លាំងកងទ័ពព្រៃទាំងខ្មែរទាំងយួន បានបង្កើនកម្លាំងគ្រប់មធ្យោបាយទាំងអស់ រួមផ្សំនឹងការថ្លែងប្រកាសលើកទឹកចិត្តពីអតីតប្រមុខរដ្ឋខ្មែរ ដែលកំពុងបញ្ចេញសកម្មភាពយ៉ាងពេញទំហឹងនៅក្រុងប៉េកាំងទាំងថ្ងៃ រហូតដល់ព្រះអង្គថ្លែងអំណរគុណដល់កងទ័ពព្រៃយួនយៀកកុងដែលបានសម្លាប់កងទ័ពជាតិខ្មែរ ក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី លន់ នល់ ដែលព្រះអង្គបានចោទថា គឺជាឆ្កែបំរើដាច់ថ្លៃរបស់ចក្រពត្រអាមេរិកាំង ហើយជាជនក្បត់ជាតិបង្កឱ្យមានកើតសង្គ្រាមនៅក្នុងស្រុកខ្មែរ ។

សង្គ្រាមបានប្រយុទ្ធយ៉ាងសាហាវឃោឃៅស្មើរស៊ីសាច់ហុតឈាមធ្វើឱ្យជីវិតកូនខ្មែរ ត្រូវបាត់បង់យ៉ាងគួរឱ្យអានោចអាធមនៅគ្រប់សមរភូមិ ពីព្រោះតែចង់ការពារប្រទេសជាតិ ឯករាជ្យជាតិ និងបូរណភាព អធិបតេយ្យភាពទឹកដី ដែលត្រូវប្រទេសយួនកុម្មុយនីស្តមានមហិច្ឆិតាលោភលន់ ចង់ពង្រីកអំណាច និងទឹកដីរបស់ខ្លួន ។

ហេតុការណ៍ទាំងអស់នេះ មានជនជាតិខ្មែរតិចណាស់ ដែលបានយល់ដឹង និងមើលឃើញពីសភាពពិតទាំងអស់នេះ ហើយមានសេចក្តីព្រួយបារម្ភសោកស្តាយនឹងការដែលត្រូវកើតមាននេះ ដោយសារតែមនុស្សកំពុងនាំគ្នាសប្បាយរីករាយខ្លាំងណាស់ នឹងការរីកចំរើនលូតលាស់យ៉ាងទាន់សម័យបំផុតនៃវិទ្យាសាស្ត្រគ្រប់វិស័យ ។ សម័យនេះវិទ្យាសាស្ត្របានជួបកែប្រែជីវភាពរបស់មនុស្ស ដូចជាការបង្កើតគ្រឿងអស្សាណូ អេឡិចត្រូនិច និងគ្រឿងបច្ចេកវិទ្យាពិសេសៗ សម្រាប់ស្រាវជ្រាវ និងកិច្ចការសំខាន់ៗនៅក្នុងគ្រប់វិស័យ ។

ការដាក់អាវុធបញ្ចប់សង្គ្រាម

ឥឡូវនេះ សូមក្រឡេកមកមើលព្រឹត្តិការណ៍ដែលកើតមាននៅក្នុងប្រទេសខ្មែរ នៅក្នុងអំឡុងឆ្នាំ ១៩៧០តទៅទៀត ។

សង្គ្រាមរវាងកងទ័ពជាតិខ្មែរ ក្រោមការដឹកនាំរបស់លោកសេនាប្រមុខ លន់ នល់ និងទ្រង់ សិរិមតៈ និងកងទ័ពព្រៃយួនយៀកកុង ខ្មែរក្រហម ក្រោមការជួយឧបត្ថម្ភ និងគាំទ្រពីអតីតប្រមុខរដ្ឋខ្មែរ ព្រមទាំងក្រុមប្រទេសកុម្មុយនីស្ត ចិន យួន និងកូរ៉េខាងជើង បានប្រយុទ្ធគ្នាគួរឱ្យប្រជាពលរដ្ឋខ្មែរខ្លាចរន្ធត់ញាប់ញ័រ និងត្រូវរងទុក្ខវេទនា ខ្លោចផ្សា ព្រាត់ប្រាសពីឪពុកម្តាយ ប្រពន្ធកូន ញាតិសន្តាន មិត្តភក្តិភូមិផងរបងជាមួយយ៉ាងច្រើនឥតគណនា បានពន្យាបន្លាយអស់រយៈពេលជាង៥ឆ្នាំ មានការខូចខាតយ៉ាងធ្ងន់ធ្ងរទាំងសងខាង និងបំផ្លាញខ្ទេចខ្ទីនូវរចនាសម្ព័ន្ធគ្រប់វិស័យ ធ្វើឱ្យប្រទេសជាតិខ្មែរ ធ្លាក់ទៅក្នុងសភាពទន់ខ្សោយ និងក្រតោកយ៉ាកលំបាកលំបិនគួរឱ្យអានោចអាធម ។

ដោយឃើញការរងទុក្ខវេទនា និងការព្រាត់ប្រាស់ការខូចខាតគ្រប់បែបយ៉ាងដូចបានរៀបរាប់ខាងលើ ទើបបណ្តាលឱ្យលោកសេនាប្រមុខ លន់ នល់ និងទ្រង់ សិរិមតៈ ព្រមទាំងសភាជាតិ និងប្រជាពលរដ្ឋខ្មែរ សម្រេចដាក់អាវុធឈប់វាយប្រហារគ្នាតទៅទៀត ដើម្បីបញ្ចប់សង្គ្រាមកុំឱ្យមានហេតុការណ៍ទាំងអស់ ដែលប៉ះពាល់ដល់សេចកញ្ញញតីរងទុក្ខវេទនាដល់ប្រជាពលរដ្ឋ និងការខូចខាតខ្ទេចខ្ទីប្រទេសតទៅទៀត ទើបលោកសេនាប្រមុខ និងទ្រង់សិរិមតៈចេញបញ្ជាដកកងទ័ពជាតិខ្មែរគ្រប់អង្គភាពត្រូវតែដាក់អាវុធចុះ

តទៅលេខក្រោយ

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ អង្គរ
Angkor International Travel Agency

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ
(Since 1991)
Angkor International Travel Agency

World Wide Travel & Tour Service
Cambodia - Vietnam - Laos - Thailand

ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ សេវាអន្តោប្រវេសន៍
សេវាលិខិតឆ្លងដែន កក់សណ្ឋាគារ ឬជួលឡាន

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

Cambodia Office: Victory Travel (Skin Belle)
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR,CHINA, ASIANA KOREAN AILINES

Khmer Music Lessons

This is a unique opportunity to try out several Khmer musical instruments among these:

◊ ***Tro** (Khmer violin)*
◊ ***Roneat** (wood xylophone)*
◊ ***Takhé** (horizontal guitar)*
◊ ***Khim** (Khmer dulcimer)*
◊ *Kong*, Ksé Diev*, Chapei**
(lessons not available)*

From September to November 2011
Every **Sunday** from 9 am to 5 pm at:
KHMER ART GALLERY
319 N. 11th Street - Philadelphia, PA 19107
☎ 215-922-5600 www.khmerartgallery.com
Contact: 215-717-7253
E-mail address: romnyneang@gmail.com

One-on-One Rate:
$30 for **45** minutes including **30** minutes for instrumental practice and **15** minutes for music theory.
Level: Beginners, children or adult.
See demo on my YouTube channel:
UnitedKhmerArtists
www.youtube.com/user/unitedkhmerartists#p/u/0/Y9gkZ8J2W8E
www.youtube.com/user/unitedkhmerartists#p/u/11/P23NkZI3zu4



តមកពីទំព័រទី ៤

អង់ទ្រូ ភ្លក់ម្ហូប សាំភ្លីខ្មែរ

អត្ថបទឱ្យអ្នកអានបានរំភើប និងរីករាយដូចបានចូលរួមភ្លក់ម្ហូបខ្មែរនៅ "សាំភ្លីខ្មែរ" ដែរ ។

ប្រហុកក្លិនស្អុយ ពោះគោ ពោះវៀន ស្ថិតនៅកន្លែងក្រខ្វក់បំផុតនៃរូបរាងកាយសត្វ ម្ទេសរស់ជាតិហិរស្ទើរសន្លប់ គឺប្រាកដជាម្ហូបចម្លែកសម្រាប់ទូរទស្សនិកជនរាប់លាននាក់នៅសហរដ្ឋនេះ តែជាម្ហូបធម្មតាសោះសម្រាប់ពលរដ្ឋខ្មែរ ហើយ "សាំភ្លីខ្មែរ" មានទេពកោសល្យបន្ថែមធ្វើឱ្យមុខម្ហូបទាំងនោះមានរស់ជាតិឈ្ងុយឆ្ងាញ់ ស្អាត ហើយសមរម អាចដាក់ជូនសាធារណៈជនហូបបានយ៉ាងពេញចិត្ត នៅពេលដែល អង់ទ្រូ ជីមមើន ឧទានបន្ទាប់ពីប្រែទឹកមុខមកញញឹម បន្ទាប់ពីភ្លក់ម្ហូបរួចហើយថា "ថ្លៃថ្នូរ ធ្វើបានដូចដើម អស្ចារ្យណាស់" នោះបានជម្រុញភាពអន្តរជាតិនិយមរបស់ម្ហូបខ្មែរ លូតបានយ៉ាងឆ្ងាយ គឺនៅពេលដែលរូបភាពនៅ "សាំភ្លីខ្មែរ" បានត្រូវផ្សាយនៅលើ "ត្រាវែលឆាណែល" ។

ក្នុងដំណើរទៅភ្លក់ម្ហូបចម្លែកនៅស្រុកខ្មែរ និងនៅ "សាំភ្លីខ្មែរ" របស់ អង់ទ្រូ បានធ្វើឱ្យគេចាប់អារម្មណ៍ថា វប្បធម៌ដ៏ចាស់ទុំរបស់ខ្មែរ ប្រាកដជាមានបន្សល់ទុកនូវមុខម្ហូបចម្លែកសម្រាប់បរទេសយ៉ាងច្រើន ឱ្យមនុស្សជំនាន់ក្រោយតែសព្វថ្ងៃនេះមានម្ចាស់ភោជនីយដ្ឋានជាច្រើនយល់ថា "ម្ហូបខ្មែរពុំអាចបំរើផ្សារសាធារណបានទេ" នៅឡើយ ។ អរគុណ "សាំភ្លីខ្មែរ" និង "ឡូសាន់" ដែលបានផ្សាយមុនគេនូវការសាកល្បង ឱ្យខ្មែរមានជំនឿលើគុណភាពម្ហូបខ្លួនឯង ៕

ការិយាល័យវេជ្ជបណ្ឌិត

ខេរិន : (267) 210 8880

ក្រុមហ៊ុនយើងមានបទពិសោធន៍ ១០ឆ្នាំក្នុងការព្យាបាល :

Slip & Fall	រអិល និងដួល
Auto Accident	គ្រោះថ្នាក់រថយន្ត
Back Pain	ឈឺខ្នង
Headache	ឈឺក្បាល
Neck Pain	ឈឺកញ្ចឹងក

- មានអ្នកបកប្រែ និយាយភាសាខ្មែរ, ខេរិន TeL: (267) 210 8880
- មានការណែនាំជូន មេធាវី ដែលមានបទពិសោធន៍ច្រើនឆ្នាំ

South Office: 215-776-6215
PAIN & INJURY
CHIROPRACTIC CENTER
1100 Washington Ave., Lot C, Unit #C2
Philadelphia, PA 19147
Tel. 215-468-7256

North Office: 267-408-6150
VN Chiropractic Center
5416 N. 5th St.
Philadelphia, PA 19120
Tel. 215-324-1400

តមកពីទំព័រទី ៨

ក្រុមអ្នកភូមិមកធ្វើការតវ៉ាពី...

តើទីកន្លែងណាដែលយើងត្រូវរើទៅនោះទេ" ។

លោក យស ភឹម ដែលមកពីឃុំបុសខ្នុរដែរនោះ បាននិយាយថា ក្រុមអ្នកភូមិទាំងនេះបានមកកាន់សួនសេរីភាព ពីព្រោះ "យើងដឹងថា នេះជាកន្លែងមួយ សម្រាប់បញ្ចេញមតិ និងរកយុត្តិធម៌" ។

លោក គីម ខុន មេឃុំបុសខ្នុរបានមានប្រសាសន៍កាលពីម្សិលមិញថា ដីដែលអ្នកភូមិរស់នៅគឺជាដីរដ្ឋ ហើយដីនេះត្រូវបានផ្ដល់ទៅឱ្យក្រុមហ៊ុនដាំកៅស៊ូមួយរួចហើយ ។

លោក ចាន់ សុវ៉េត មន្ត្រីកម្មវិធីផ្នែកឃ្លាំមើលរបស់អង្គការអាដហុកបានមានប្រសាសន៍ថា "ក្រុមអ្នកភូមិទាំងនេះមានការភ័យខ្លាចចំពោះក្រុមអាជ្ញាធរនៅក្នុងខេត្តរបស់ខ្លួន ។ ពួកគាត់បានមកសួនសេរីភាព ពីព្រោះទីនេះគឺជាជម្រើសចុងក្រោយរបស់ពួកគាត់ ។ ពួកគាត់នឹងនៅតែមកកាន់ទីនេះទៀតរហូតដល់ពួកគាត់ទទួលបានដំណោះស្រាយមួយ" ។

ក្នុងវិវាទដីធ្លីមួយផ្សេងទៀត អ្នកភូមិចំនួន៧២នាក់ដែលមកពីខេត្តកណ្ដាលបានធ្វើការតវ៉ាកាលពីម្សិលមិញ ពីព្រោះអតីតមន្ត្រីមូលដ្ឋានមួយរូបបានរានដីទំហំ២៣ហិកតា ដែលប្រជាពលរដ្ឋចំនួន១១៤គ្រួសារបានរស់នៅចាប់តាំងពីឆ្នាំ១៩៧៩មក ។

កាលពីខែកក្កដា ឆ្នាំ២០១០ សាលាដំបូងខេត្តកណ្ដាលបានសម្រេចផ្ដល់ដីនេះឱ្យលោក ប្រាក់ សារុំធ អតីតអភិបាលរងស្រុកកៀនស្វាយ បន្ទាប់ពីជម្លោះពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លីជាមួយក្រុមអ្នកភូមិបានអូសបន្លាយចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០មក ។

អ្នកស្រី ជឹម សារុន ជាអ្នកភូមិម្នាក់មកពីឃុំសំរោងធំបានឱ្យដឹងថា "យើងនឹងគ្មានដីដើម្បីធ្វើស្រែក្នុងរដូវវស្សានេះទេ" ។ អ្នកស្រីបានបន្តថា ក្រុម. អ្នកភូមិត្រូវបានគំរាមកំហែងចាប់ខ្លួនដោយក្រុមអាជ្ញាធរ ។

ក្រុមអ្នកភូមិបានឱ្យដឹងថា គ្រួសារអ្នកភូមិនៅឃុំសំរោងធំ ក្នុងមួយគ្រួសារៗបានទទួលប្រាក់ចំនួន២៥០ដុល្លារពីលោក ប្រាក់ សារុំធ សម្រាប់ដីរបស់ពួកគាត់ ប៉ុន្តែពុំទាន់បានទទួលដីថ្មីណាមួយដើម្បីរស់នៅនៅឡើយទេ ។

អ្នកស្រី ជឹម សារុន បាននិយាយថា "យើងចង់ជម្រាបសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យដឹងថា យើងចង់បានដីរបស់យើងមកវិញ ហើយយើងមានការភ័យខ្លាចជារៀងរាល់ថ្ងៃ" ។

លោក ហេង ហៀម អភិបាលខេត្តកណ្ដាលបានបដិសេធថា នគរបាលពុំបានធ្លាប់គំរាមកំហែងក្រុមអ្នកភូមិណាដែលពាក់ព័ន្ធនឹងជម្លោះដីធ្លីនោះទេ ៕

មន្ទីរសុខភាព ART OF WELLNESS CENTER

647 Bainbridge St. Phila PA., 19147 215-305-2238

ទទួលព្យាបាលខ្លួន និងបញ្ញាផ្លូវចិត្តធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នកដោយប្រើរបៀបបច្ចេកទេសអាស៊ីនិងបច្ចេកវិទ្យាបច្ចឹមប្រទេស ។

ភាសាខ្មែរទាក់ទង ប៊ុន រ៉ាត់ : 267-242-8526

ទទួលព្យាបាលគ្រប់វ័យ

- ប្រើម្ជុលឥតថ្នាំ • ចាប់សរសៃ • ចិត្តវិទ្យា • យោគ/ភាវនា

TREATMENT TYPE

- Acupuncture • Acupressure • Psychotherapy • Yoga/ Meditation

www.artofwellnesscenter.com

ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម :

Weight Management for Adult & Children	គ្រប់គ្រងទម្ងន់សម្រាប់ចាស់និងក្មេង	Insomnia (Difficulty Sleeping)	ដេកមិនលក់
Diabetes	ទឹកនោមផ្អែម	Feeling Tired & Weak	អស់កម្លាំង មិនស្រួលខ្លួន
High Blood Pressure	លើសសម្ពាធឈាម	Stress /Anxiety	ភាពតានតឹង/ការថប់អារម្មណ៍
High Cholesterol Level Issue	លើសកំរិត កូលេសស្តេរ៉ូល	Depression	ធ្លាក់ទឹកចិត្ត
Pain Management	ឈឺខ្លួនប្រាណគ្រប់កន្លែង	Family Issues	មានវិបត្តិក្នុងគ្រួសារ
Nutrition Consultation (Free)	ពិគ្រោះពីម្ហូបអាហារ (មិនយកកំរៃ)	Addiction Issues	ការញៀន និងអ្វីមួយ
Women´s Health	សុខភាពស្ត្រី	Anger Management	មានកំហឹងច្រើន

យើងទទួលយក AETNA នឹង UNITED HEALTHCARE CIGNA

Yoo's Auto Service and Collision
យូ បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច

FREE ESTIMATES

យើងអាចជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក
ឱ្យបានប្រសើរបំផុត ដើម្បីសុវត្ថិភាពលោកអ្នក
មិនឱ្យខុសចិត្តឡើយ ។

ផ្នែកជាងម៉ាស៊ីន
Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Inspection & Repairs
Muffler & More

ផ្នែកជួសជុលតួរថយន្ត
Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists

189 W. Duncannon Ave. Phila., PA 19120
ទូរស័ព្ទរក SAM 215-457-7777 ឬ
215-457-7779, Fax-215-457-7475

សូមអញ្ជើញមកលំហែរអារម្មណ៍
កំចាត់ភាពអាប់អួរ!
ភោសជ្ជៈដ្ឋាន ហ្វៀ

Bar's Open
Monday-Saturday
10a.m.–2a.m.
Sunday
11a.m.–2a.m.

198 W. Godfrey Avenue.
(Corner of Godfrey & 2nd St.)

Philadelphia, PA 19120
215-621-7563

តមកពីទំព័រទី ៥

ក្រុងខ្មែរ នៅឡុងប៊ិច និង...

ជាងតំបន់ឯទៀតៗនៃស.រ.អា។

ឡូវែល : ក្រុងឡូវែល គឺជាក្រុងដែលមានសហគមន៍ខ្មែរច្រើនលំដាប់លេខ២ដែលមានពលរដ្ឋខ្មែរប្រមាណជា៣ម៉ឺនរស់នៅចាស់ឆ្នាំដូចគ្នានឹងក្រុងឡុងប៊ិចដែរ ។ ឥឡូវនេះសហគមន៍ខ្មែរកំពុងធ្វើការឃោសនាយ៉ាងខ្លាំងក្លា ដើម្បីបង្កើតក្រុងខ្មែរជាលើកទីពីរនៅស.រ.អា នេះ។

ព័ត៌មានដែលយើងទទួលបានក្រៅផ្លូវការថា "ក្រុងខ្មែរ" នៅឡូវែលបានទទួលការសម្រេចវិជ្ជមានពីគណក្រុមប្រឹក្សាក្រុងឡូវែលរួចហើយនាពេលថ្មីៗនេះ ។ យើងនឹងតាមដានយកព័ត៌មាននេះមកជូនលោកអ្នកអានជាបន្តទៅទៀតនៅពេលក្រោយ ៕



រូបថតផ្សាយដោយសមាគមខ្មែរនៅឡូវែល

ហាងមាសខ្មែរអង្គរ
Khmer-Angkor
金美成珠寶行 Jewelry
Since 1983
Certified Diamonds
